# ធ្វើតេស្តរកជំងឺរលាកថ្លើមប្រភេទ B

ជំងឺរលាកថ្លើមប្រភេទ B គឺជាវីរុសដែលបំផ្លាញថ្លើម។ ជំងឺរលាកថ្លើមប្រភេទ B អាចបណ្តាលឱ្យកើតមានជំងឺមហារីកថ្លើម ប៉ុន្តែមានវិធីព្យាបាលដែលអាចជួយរក្សាថ្លើមរបស់អ្នកឱ្យមានសុខភាពល្អបាន។

ជាធម្មតា អ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B មិនមានរោគសញ្ញាទេ ប៉ុន្តែពួកគេអាចចម្លងជំងឺនេះទៅកាន់អ្នកដទៃបាន។

មានវ៉ាក់សាំងដែលមានសុវត្ថិភាព និងមានប្រសិទ្ធភាពដែលអាចបង្ការពីជំងឺរលាកថ្លើមប្រភេទ B បាន។

## ជំងឺរលាកថ្លើមប្រភេទ B ឆ្លងពី៖

ការឆ្លងពីម្តាយទៅទារកក្នុងអំឡុងពេលសម្រាលកូន

ការប៉ះពាល់ឈាមអ្នកដែលមានជំងឺរលាកថ្លើមប្រភេទ B

ការរួមភេទ

ការប្រើប្រាស់របស់របរផ្ទាល់ខ្លួនរួមគ្នា ដូចជាឡាមកោរ ច្រាសដុសធ្មេញ ឬកន្ត្រៃកាត់ក្រចក

## ជំងឺរលាកថ្លើមប្រភេទ B មិនឆ្លងតាមរយៈ៖

ការបរិភោគអាហារ ឬប្រើប្រាស់សម្ភារៈផ្ទះបាយរួមគ្នា

ការប៉ះពាល់ធម្មតាដូចជាការឱប ការថើប ឬការកាន់ដៃ

ទឹក ឬ ខ្យល់

## អ្នកដែលគួរត្រូវបានធ្វើតេស្តរកជំងឺរលាកថ្លើមប្រភេទ B៖

- ស្ត្រីមានផ្ទៃពោះ
- អ្នកដែលរស់នៅជាមួយអ្នកកើតជំងឺរលាកថ្លើមប្រភេទ B
- អ្នកដែលកើតនៅក្នុងតំបន់ដែលមានការឆ្លងជំងឺរលាកថ្លើមប្រភេទ B ច្រើនដូចជាទ្វីបអាហ្វ្រិក ឬអាស៊ី
- អ្នកដែលមានឪពុកម្តាយមកពីតំបន់ដែលមានការឆ្លងជំងឺរលាកថ្លើមប្រភេទ B ច្រើនដូចជាទ្វីបអាហ្វ្រិក ឬអាស៊ី

DEPARTMENT OF HEALTH

PO Box 64975 St. Paul, MN 55164-0975
651-201-5414 or 1-877-676-5414
www.health.state.mn.us/hepatitis
4/2026